ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៧.ប្រភ.ព.

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩

នៅព្រឹកថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។

២-បញ្ហាផ្សេងៗ៖

សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ៖

- ២.១.កិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។
- ២.២.សន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ នៅហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

ច្បាប់ស្តីពីសហជីព គឺជាច្បាប់ដ៏មានសារៈសំខាន់ក្នុងការធានាសិទ្ធិសេរីភាពវិជ្ជាជីវៈដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការងារ ព្រមទាំងអនុសញ្ញាអន្តរជាតិខាងការងារ លេខ៨៧ ស្តីពីសេរីភាពនៃសមាគមនិងការការពារសិទ្ធិនៃការបង្កើតសមាគម និងលេខ៩៨ ស្តីពីសិទ្ធិនៃការ

បង្កើតសមាគមនិងសិទ្ធិនៃការចរចាជាសមូហភាព ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ការបន្តការពង្រឹងនូវការអនុវត្តច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព តាមរយៈការពង្រឹងប្រសិទ្ធភាពប្រព័ន្ធអធិការកិច្ចការងារ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធានាភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងការលើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជា។ ជាក់ស្តែង គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩នេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះបញ្ជីអង្គការវិជ្ជាជីវៈសរុបចំនួន៥១៧ ក្នុងនោះសហជីពមូលដ្ឋានចំនួន ៤៩០១ សហព័ន្ធសហជីពចំនួន២០៤ សហភាពសហជីពចំនួន៣១ និងសមាគមនិយោជកចំនួន១១។

ទន្ទឹមនឹងវឌ្ឍនភាពជារំជួមាន សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មចំនួន១០មាត្រាដែលមាន មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីពដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦ ដែលមាន១០០មាត្រានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសម្រួលដល់ការអនុវត្តសិទ្ធិសេរីភាពរបស់អង្គការវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនៃការវិវឌ្ឍផ្នែកសង្គមនិងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន តាមរយៈ ១).-លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈរបស់អ្នកបម្រើក្នុងផ្ទះ ២).-សម្រួលនីតិវិធីនៃការចុះបញ្ជីសហជីព ៣).-សម្រួលនីតិវិធីនៃការរក្សាបញ្ជិកា និងការរំលាយអង្គការវិជ្ជាជីវៈ ៤).-សម្រួលក្នុខណ្ឌក្នុងការស្នើសុំទទួលស្គាល់ភាពជាតំណាងបំផុត និង ៥).-លើកកម្ពស់សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចឱ្យកាន់តែច្បាស់លាស់ ដោយបន្ថែមចំណុចការធ្វើជាតំណាងសមាជិករបស់ខ្លួនក្នុងការដោះស្រាយវិវាទការងារួមដែលកើតចេញពីការមិនអនុវត្តអនុសញ្ញារួម។

សេចក្តីព្រាងច្បាប់នេះ គឺជាសមិទ្ធផលគតិយុត្តថ្មីមួយទៀតក្នុងការចូលរួមគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ស្របតាមការអនុវត្តគោលនយោបាយនៃការផ្សារភ្ជាប់ពាណិជ្ជកម្មអន្តរជាតិទៅនឹងលក្ខខណ្ឌការងារ ដែលបានលើកកម្ពស់កិត្យានុភាពកម្ពុជាក្នុងការប្រកួតប្រជែង ទាក់ទាញវិនិយោគ និងបង្កើតការងារជូនកម្មករនិយោជិត។

២-បញ្ហាផ្សេងៗ៖

២.១.អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចបញ្ជូនទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ៖

១).-កិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

២).-សន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ នៅហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។

២.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- ទោះបីក្នុងតម្លៃណាក៏ដោយ មិនអនុញ្ញាតឱ្យផែនការរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់កើតឡើងជាដាច់ខាត ហើយក៏មិនអត់ឱនឱ្យដែរ។ រាជរដ្ឋាភិបាលអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់បំផុតចំពោះជនទាំងឡាយណាដែលចូលរួម៖

- ប្រព្រឹត្តអំពើក្បត់ជាតិក្នុងការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់
- ផ្សព្វផ្សាយផែនការរដ្ឋប្រហារតាមបណ្តាញទំនាក់ទំនងសង្គមនានា
- ទៅទទួលដំណើរជនក្បត់ជាតិ សមរង្ស៊ី នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

- ព្រះរាជាណាចក្រកម្ពុជាត្រៀមទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម János Áder ប្រធានាធិបតីប្រទេសហុងគ្រី នៅថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩នេះ។

- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិត្រូវសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ១៤កើត ថ្ងៃចន្ទ១៥កើត និងថ្ងៃអង្គារ១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ទី១១ និងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឱ្យបានល្អអធិកអធម សប្បាយរីករាយ និងប្រកបដោយជោគជ័យ ទោះបីកម្រិតទឹកទន្លេក្នុងឆ្នាំនេះទាបជាងឆ្នាំកន្លងទៅក៏ដោយ។

- ព្រះរាជាណាចក្រកម្ពុជាបានទទួលការគាំទ្រពីសហគមន៍អន្តរជាតិ ឱ្យធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ។

- រាជរដ្ឋាភិបាលធ្វើការបែងចែកអាវរងាដែលមានស្រាប់ចំនួន ៤០.០០០អាវ ជូនដល់កងកម្លាំងប្រដាប់អាវុធទិសភូមិភាគទី១ ភូមិភាគទី៤ និងភូមិភាគទី៥ ព្រមទាំងបែងចែកបន្តបន្ទាប់រហូតដល់គ្រប់៨០.០០០អាវ ជូនដល់កងកម្លាំងប្រដាប់អាវុធគ្រប់ទិសដែលបាននិងកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែន និងតាមបណ្តាកោះក្នុងដែនសមុទ្រកម្ពុជា ដែលតែងតែខិតខំថែរក្សាការពារសុខសន្តិភាពនិងបូរណភាពទឹកដីជាតិមាតុភូមិដោយអង់អាចក្លាហាននិងឥតងាករេ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង៩និង៤០នាទី។

ថ្ងៃសុក្រ ១៣កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩